# ការប្រឡងតាមជំពូក

## ការណែនាំ

នៅពេលដែលអ្នកបានបញ្ចប់ការសិក្សារបស់អ្នកទៅតាមជំពូកនីមួយៗហើយ ចូរឆ្លើយសំណួរប្រឡងតាមជំពូក ដោយប្រើប្រាស់ក្រដាសចម្លើយទៅតាមលំហាត់ប្រឡងជំពូកនីមួយៗ ដើម្បីកត់ត្រាចម្លើយរបស់អ្នក។

សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយតែមួយគត់ដែលល្អជាងគេសម្រាប់សំណួរនីមួយៗ។ ចូរផាត់ពណ៌ខ្មៅទៅលើប្រឡោះចម្លើយដែលអ្នកជ្រើសរើស។ *ត្រូវតែប្រាកដថាលេខនៅក្នុងក្រដាសចម្លើយដូចទៅនឹងលេខនៅក្នុងសំណួរដែលអ្នកឆ្លើយ។*

## ឧទាហរណ៍

១ ការកើតជាថ្មីគឺមានន័យថា

ក) មានអាយុតិច

ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ

គ) ចាំផ្តើមឆ្នាំថ្មី

ឃ) ស្វែងរកក្រុមជំនុំផ្សេងមួយទៀត

ចម្លើយដែលត្រឹមត្រូវគឺ ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ ដូច្នេះអ្នកត្រូវផាត់ពណ៌ខ្មៅនៅក្នុងចន្លោះអក្សរ ខ យ៉ាងដូច្នេះ៖

១ (ក) ● (គ) (ឃ)

## ការប្រគល់ ចម្លើយសម្រាប់ការប្រឡង

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ និង បានឆ្លើយសំណួរប្រឡងទាំងអស់ហើយ សូមផ្ញើក្រដាសចម្លើយរបស់អ្នកទៅឲ្យគ្រូ ឬ ការិយាល័យដែលនៅក្នុងតំបន់របស់អ្នកដើម្បីធ្វើការកែសម្រួល។

# ក្រដាសចម្លើយការប្រឡងតាមជំពូក

## CS3131 ថ្មគ្រឹះនៃសេចក្ដីពិត

## ព័ត៌មានរបស់សិស្ស

ឈ្មោះ.............................................................................................................

លេខសំគាល់របស់សិស្ស...................................................................................

(សូមរក្សាចន្លោះនេះឲ្យនៅទទេ បើអ្នកមិនស្គាល់លេខរបស់អ្នក)

អាសយដ្ឋាន......................................................................................................

.........................................................................................................................

.........................................................................................................................

ប្រទេស..........................................................................................................

អ៊ីម៉ែល...........................................................................................................

**ចូរផាតពណ៌ខ្មៅដោយប្រុងប្រយ័ត្ននៅក្នុងចន្លោះចម្លើយត្រឹមត្រូវ របស់សំណួរដែលមានលេខដូចគ្នា។**

## ជំពូកទីមួយ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ក | ខ | គ | ឃ | ១១ | ក | ខ | គ | ឃ |
| ២ | ក | ខ | គ | ឃ | ១២ | ក | ខ | គ | ឃ |
| ៣ | ក | ខ | គ | ឃ | ១៣ | ក | ខ | គ | ឃ |
| ៤ | ក | ខ | គ | ឃ | ១៤ | ក | ខ | គ | ឃ |
| ៥ | ក | ខ | គ | ឃ | ១៥ | ក | ខ | គ | ឃ |
| ៦ | ក | ខ | គ | ឃ | ១៦ | ក | ខ | គ | ឃ |
| ៧ | ក | ខ | គ | ឃ | ១៧ | ក | ខ | គ | ឃ |
| ៨ | ក | ខ | គ | ឃ | ១៨ | ក | ខ | គ | ឃ |
| ៩ | ក | ខ | គ | ឃ | ១៩ | ក | ខ | គ | ឃ |
| ១០ | ក | ខ | គ | ឃ | ២០ | ក | ខ | គ | ឃ |

**សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ គ្លូបល**

ថ្ងៃទី ............................................ពិន្ទុ.....................................................

PN01.25.01

# ជំពូកទីពីរ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ក | ខ | គ | ឃ | ១១ | ក | ខ | គ | ឃ |
| ២ | ក | ខ | គ | ឃ | ១២ | ក | ខ | គ | ឃ |
| ៣ | ក | ខ | គ | ឃ | ១៣ | ក | ខ | គ | ឃ |
| ៤ | ក | ខ | គ | ឃ | ១៤ | ក | ខ | គ | ឃ |
| ៥ | ក | ខ | គ | ឃ | ១៥ | ក | ខ | គ | ឃ |
| ៦ | ក | ខ | គ | ឃ | ១៦ | ក | ខ | គ | ឃ |
| ៧ | ក | ខ | គ | ឃ | ១៧ | ក | ខ | គ | ឃ |
| ៨ | ក | ខ | គ | ឃ | ១៨ | ក | ខ | គ | ឃ |
| ៩ | ក | ខ | គ | ឃ | ១៩ | ក | ខ | គ | ឃ |
| ១០ | ក | ខ | គ | ឃ | ២០ | ក | ខ | គ | ឃ |

**សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ គ្លូបល**

ថ្ងៃទី ..........................................ពិន្ទុ..................................................

# ជំពូកទីបី

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ក | ខ | គ | ឃ | ១១ | ក | ខ | គ | ឃ |
| ២ | ក | ខ | គ | ឃ | ១២ | ក | ខ | គ | ឃ |
| ៣ | ក | ខ | គ | ឃ | ១៣ | ក | ខ | គ | ឃ |
| ៤ | ក | ខ | គ | ឃ | ១៤ | ក | ខ | គ | ឃ |
| ៥ | ក | ខ | គ | ឃ | ១៥ | ក | ខ | គ | ឃ |
| ៦ | ក | ខ | គ | ឃ | ១៦ | ក | ខ | គ | ឃ |
| ៧ | ក | ខ | គ | ឃ | ១៧ | ក | ខ | គ | ឃ |
| ៨ | ក | ខ | គ | ឃ | ១៨ | ក | ខ | គ | ឃ |
| ៩ | ក | ខ | គ | ឃ | ១៩ | ក | ខ | គ | ឃ |
| ១០ | ក | ខ | គ | ឃ | ២០ | ក | ខ | គ | ឃ |

**សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ គ្លូបល**

ថ្ងៃទី ..........................................ពិន្ទុ..................................................

# ការប្រឡងជំពូកទីមួយ

១ គុណលក្ខណៈរបស់ព្រះជាម្ចាស់ដែលបង្ហាញពីភាពជាបុគ្គលរបស់ទ្រង់ គឺ

ក) លក្ខណៈខាងឯសាច់ឈាម សង្គម និង វិញ្ញាណ

ខ) សមត្ថភាពក្នុងការគិត មានអារម្មណ៍និង ធ្វើការសម្រេចចិត្ត

គ) ភាពដែលអាចឲ្យគេចូលមករក អាចឃើញ និង យល់ពីទ្រង់បាន។

ឃ) លក្ខណសម្បត្តិដ៏អាថ៌កំបាំង ដូចដែលបានឃើញនៅក្នុងព្រះរូបសំណាក់ពីបុរាណមក។

២ ការមើលទៅកាន់បុគ្គលិកលក្ខណៈរបស់មនុស្ស បង្រៀនយើងអំពីបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ ព្រោះ

ក) យើងដឹងនៅក្នុងចិត្តយើងយ៉ាងច្បាស់ ថាព្រះជាម្ចាស់ជាព្រះបែបណាទៅហើយ។

ខ) បុគ្គលិកលក្ខណៈរបស់មនុស្សគឺដូចជាបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ទាំងស្រុង

គ) បុគ្គលិកលក្ខណៈរបស់យើងឆ្លុះបញ្ចាំងពីអ្វីដែលយើងចង់ឃើញពីព្រះជាម្ចាស់។

ឃ) យើងត្រូវបង្កើតមកឲ្យមានសណ្ឋានរបស់ព្រះជាម្ចាស់ និង មានលក្ខណៈស្រដៀងទ្រង់។

៣ នៅពេលដែលយើងនិយាយអំពីចំណុចពិសេសដោយឡែក ភាពសាមញ្ញ និង ការរួមមកតែមួយរបស់ព្រះជាម្ចាស់ យើងចង់បានន័យថា

ក) ព្រះជាម្ចាស់តែមួយ។

ខ) ព្រះជាម្ចាស់ដែលធំជាងគេនៅក្នុងចំណោមព្រះជាច្រើន។

គ) ស្ទើរតែដូចទៅនឹង ភាវៈដែលជាស្នាព្រះហស្តរបស់ទ្រង់។

ឃ) ទ្រង់មានភាពខុសគ្នាដាច់ស្រឡះ។

៤ រឿងពិតមួយអំពីព្រះជាម្ចាស់ដែលមនុស្សអាចដឹងបាន តាមរយៈការបើកសម្តែងរបស់ព្រះជាម្ចាស់តែមួយគត់នោះគឺ សេចក្តីបង្រៀនអំពី

ក) ការរួមមកតែមួយរបស់ព្រះជាម្ចាស់

ខ) ភាពឧត្តុង្គឧត្តមរបស់ព្រះយេស៊ូ

គ) ការរួមបីមកតែមួយ ឬ ត្រីឯក

ឃ) ពេលវេលាជាក់លាក់ដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញ។

៥ នៅពេលដែលយើងនិយាយថាព្រះជាម្ចាស "ខ្ជាប់ខ្ជួន" យើងចង់មានន័យថា ទ្រង់គឺ

ក) នៅតែល្អឥតខ្ចោះ

ខ) នៅតែបន្តបង្កើត

គ) អាថ៌កំបាំងសម្រាប់យើង

ឃ) មិនចេះផ្លាស់ប្រែ

៦ ដោយទ្រង់ជាព្រះដ៏វិសុទ្ធ នោះអ្វីគ្រប់យ៉ាងដែលទ្រង់ធ្វើគឺ
  ក) ត្រឹមត្រូវ និង ល្អ
  ខ) ស្លូតបូត និង រាបសា
  គ) ជាអាថ៌កំបាំងសម្រាប់យើង
  ឃ) តែងតែចាំចាប់កំហុស

៧ យោងទៅតាមគម្ពីររ៉ូម ១:១៨-២០ កិច្ចការរបស់ព្រះជាម្ចាស់ ក្នុងការបង្កើតគឺជាការបើកសម្តែងទូទៅនៃ
  ក) ភាពវិសុទ្ធ និង ភាពយុត្តិធម៌របស់ទ្រង់
  ខ) ក្តីស្រឡាញ់ក្នុងនាមជាឪពុកសម្រាប់អ្វីៗទាំងអស់ដែលទ្រង់បង្កើត។
  គ) ឫទ្ធានុភាពដ៏អស់កល្បជានិច្ច និង និស្ស័យជាព្រះជាម្ចាស់របស់ទ្រង់។
  ឃ) ឫទ្ធានុភាពដ៏អស់កល្បជានិច្ច និង ភាពសុចរិតរបស់ទ្រង់។

៨ គម្ពីរ២កូរិនថូស ៥:១៧ ប្រាប់យើងថា កិច្ចការនៃការបង្កើតរបស់ព្រះជាម្ចាស់ គឺនៅតែបន្តធ្វើឡើងនៅ
  ក) កាឡាក់ស៊ីដ៏សែនឆ្ងាយ
  ខ) ជីវិតរបស់ទេវតា
  គ) ចំណុចកណ្តាលនៃផែនដី
  ឃ) អស់អ្នកដែលទទួលព្រះគ្រិស្ត

៩ កិច្ចការរបស់ព្រះជាម្ចាស់ ក្នុងការសម្រេចបំណងព្រះហឫទ័យដ៏ឧត្តមរបស់ទ្រង់នៅក្នុងស្នាព្រះហស្តរបស់ទ្រង់ គឺត្រូវបានគេហៅថា
  ក) បុព្វជ្ញាកម្ម
  ខ) ការទស្សន៍ទាយ
  គ) ដែលមានចិត្តចង្អៀត
  ឃ) ឧបការគុណ

១០ នៅពេលដែលមានរឿងកើតឡើងដែលយើងមិនអាចយល់បាន យើងត្រូវ
  ក) ទុកចិត្តលើក្តីស្រឡាញ់ និង ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។
  ខ) ទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យអ្វីៗ បានសមតាមអ្វីដែលយើងចង់បាន។
  គ) មិនត្រូវបណ្តោយឲ្យខ្លួនយើង មានអារម្មណ៍ខឹង និង មួម៉ៅឡើយ។
  ឃ) បោះបង់ចោល និង ដាក់ខ្លួនយើងឲ្យរងទុក្ខ ឬទទួលភាពអយុត្តិធម៌ទៅចុះ។

១១ ការចាប់បដិសន្ធិ គឺមានភាពចាំបាច់ណាស់ ដើម្បីឲ្យព្រះជាម្ចាស់អាច

ក) ឆ្លងកាត់សេចក្តីល្បួង អំពើបាប និង ភាពទន់ខ្សោយរបស់មនុស្សដោយផ្ទាល់។

ខ) ប្រទាននូវការបូជា ដើម្បីបង់ថ្លៃជួសអំពើបាបរបស់យើង។

គ) ក្លាយទៅជាអ្វីម្យ៉ាងដែលយើងអាចថ្វាយបង្គំបាន។

ឃ) ត្រួតពិនិត្យមើល តម្លៃនៃស្នាព្រះហស្តរបស់ទ្រង់។

១២ នៅក្នុងគម្ពីរម៉ាថាយ និង លូកា ពង្សាវតាររបស់ព្រះយេស៊ូបង្ហាញថាទ្រង់

ក) មានបុព្វបុរសដែលជាមនុស្ស ដែលមានភាពល្បីល្បាញ តែឈ្មោះប៉ុណ្ណោះ។

ខ) គ្រាន់តែសម្តែងជាទិដ្ឋភាពមួយនៃមនុស្សតែប៉ុណ្ណោះ។

គ) កើតមកពីគ្រួសារដែលមិនច្បាស់លាស់មួយ។

ឃ) មានបុព្វបុរសជាមនុស្សពិតៗ។

១៣ ចូរអានគម្ពីរម៉ាកុស ២:៥ ។ តើអ្វី ជាសិទ្ធិជាព្រះ ដែលព្រះយេស៊ូបានប្រើប្រាស់?

ក) ទ្រង់បានបង្កើតជីវិតថ្មី

ខ) ទ្រង់បានដកយកជីវិតរបស់មនុស្ស

គ) ទ្រង់បានអត់ទោសបាបរបស់បុរសម្នាក់

ឃ) ទ្រង់បានធ្វើឲ្យព្យុះស្ងាប់

១៤ សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ អំពីការចាប់បដិសន្ធិ បង្ហាញថា ព្រះយេស៊ូ

ក) ជាព្រះជាម្ចាស់គ្រប់លក្ខណៈ និង មនុស្សគ្រប់លក្ខណៈ។

ខ) ពិតជាព្រះជាម្ចាស់ តែមិនមែនជាមនុស្សពិតនោះទេ។

គ) បានលះបង់និស្ស័យជាមនុស្សរបស់ទ្រង់ ដើម្បីទទួលបាននិស្ស័យរបស់ព្រះ។

ឃ) គឺពិតជាមនុស្ស នៅមុនពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយក្លាយជាព្រះពិតប្រាកដក្រោយពេលទ្រង់មានព្រះជន្មរស់ឡើងវិញ។

១៥ ចំណុចដ៏សំខាន់មួយនៃការចាប់បដិសន្ធិ គឺថា តាមរយៈព្រះយេស៊ូយើងឃើញ

ក) ថាព្រះជាម្ចាស់ អាចនឹងមានដែនកំណត់បែបណា។

ខ) ថាព្រះជាម្ចាស់មានឫទ្ធានុភាព តែទ្រង់ស្ថិតនៅឆ្ងាយបែបណា។

គ) ព្រះពិរោធរបស់ព្រះជាម្ចាស់ មកលើពួកយើង

ឃ) ការបើកសម្តែងយ៉ាងពេញលេញ អំពីព្រះជាម្ចាស់ និង ក្តីស្រឡាញ់របស់ទ្រង់។

១៦ គម្ពីរម៉ាថាយ ២៨:១៩ បានបង្ហាញថាព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ ដោយសារតែ
- ក) ការចូលរួមរបស់ទ្រង់ជាមួយនឹងការជ្រមុជទឹក។
- ខ) ការចូលរួមរបស់ទ្រង់ជាមួយនឹងព្រះវរបិតា និង ព្រះរាជបុត្រា
- គ) ការដែលទ្រង់ព្រមឲ្យហៅព្រះនាមទ្រង់ ក្រោយព្រះវរបិតា និង ព្រះរាជបុត្រា
- ឃ) លក្ខណៈដែលមិនអាចមើលឃើញ របស់ទ្រង់ និង លទ្ធភាពក្នុងការធ្វើកិច្ចការប្រកបដោយឫទ្ធានុភាព នៅក្នុងធម្មជាតិ។

១៧ គម្ពីររ៉ូម៨:២៧ និយាយសំដៅទៅទិដ្ឋភាពមួយណានៃបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
- ក) បំណងព្រះហឫទ័យ
- ខ) ព្រះប្រាជ្ញាញាណ
- គ) មនោសញ្ចេតនា
- ឃ) ភាពអាថ៌កំបាំង

១៨ គម្ពីរអេភេសូ ៤:៣០ លក្ខណសម្បត្តិផ្ទាល់មួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធគឺ
- ក) ការដែលទ្រង់អាចទទួលភាពសោកសៅ។
- ខ) ការដែលទ្រង់អាចបង្ហាញសេចក្តីស្រឡាញ់។
- គ) មានការអត់ធ្មន់ជាមួយនឹងអំពើបាប។
- ឃ) ចេះកំប្លែងលេង

១៩ គម្ពីរយ៉ូហាន ១៦:១៣ និយាយអំពីមុខងារដ៏មានសារៈសំខាន់របស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់អ្នកជឿ ក្នុងនាមជា
- ក) អ្នកវិនិច្ឆ័យទោស នៅពេលដែលយើងប្រព្រឹត្តិអំពើបាប។
- ខ) ព្រះដែលចាំដាក់ទោសយើង។
- គ) ជាមិត្តជិតដិតរបស់យើង។
- ឃ) ជាគ្រូម្នាក់។

២០ ទំនាក់ទំនងដ៏ស្អិតរមួតរវាងព្រះវិញ្ញាណដ៏វិសុទ្ធ និង អ្នកជឿ គឺត្រូវបានគេហៅថា
- ក) ការលិចចុះ ការបំពេញ និង ការជ្រមុជ
- ខ) មិត្តភាពយ៉ាងស្និទ្ធស្នាល
- គ) ការដើរនៅក្នុងជំនឿ
- ឃ) ការល្បងលដ៏អស្ចារ្យមួយ។

# ការប្រឡងជំពូកទីពីរ

១ នៅក្នុងភាសាដើម របស់ព្រះគម្ពីរ ពាក្យថា "ទេវតា" គឺមានន័យថា
- ក) ភាវៈដ៏វិសុទ្ធ
- ខ) អ្នកនាំសារ
- គ) មានគ្រប់ឫទ្ធានុភាព
- ឃ) ភាវៈដែលមានស្លាប

២ យើងអាចធ្វើការសន្និដ្ឋាន ចេញពីក្នុងភស្តុតាងនៃព្រះគម្ពីរអំពីដើមកំណើតរបស់ទេវតា ដែលថាពួកគេ
- ក) ភាវៈដែលត្រូវបានបង្កើតមកឲ្យមានជីវិតអមតៈ នឹងមិនបាត់ទៅណាឡើយ។
- ខ) អំបូរភាវៈដ៏អាថ៌កំបាំង ដែលស្រដៀងទៅនឹងអាទិទេពដែរ។
- គ) ភាវៈមិនចេះស្លាប់ ដែលតែងតែមានជីវិតជារៀងរហូត។
- ឃ) វិញ្ញាណរបស់មនុស្សដែលត្រូវបានធ្វើឲ្យមានសិរីរុងរឿង។

៣ ទេវតាអាក្រក់គឺត្រូវបានបង្ហាញឲ្យឃើញ តាមរយៈភាពចចេស និង ការបះបោររបស់ពួកគេ ដែលមានន័យថាពួកគេ
- ក) គឺអាក្រក់តាំងតែពីដើមមក ប៉ុន្តែបានលាក់បាំងនិស្ស័យអាក្រក់របស់ពួកគេ។
- ខ) គឺត្រូវបានបង្កើតមកបែបនេះ ហើយពួកគេមិនអាចផ្លាស់ប្តូរបានទេ។
- គ) ធ្វើការជ្រើសរើស ប្រឆាំងនឹងព្រះជាម្ចាស់ និង ត្រូវបានប្រឈមមកនឹងការកាត់ទោសអស់កល្បជានិច្ច។
- ឃ) ស្ថិតនៅក្នុងដំណាក់កាលដកពិសោធន៍ បន្ទាប់ពីនេះ ពួកគេនឹងមានឱកាសលន់តួបាប។

៤ យោងទៅតាមគម្ពីរម៉ាកុស ជំពូក៨:៣៨ ទេវតាដ៏វិសុទ្ធគឺនៅជាមួយព្រះជាម្ចាស់នាស្ថានបរមសុខ ហើយនឹង
- ក) ត្រឡប់មកវិញជាមួយព្រះគ្រិស្តដែលប្រកបដោយសិរីរុងរឿងរបស់ទ្រង់។
- ខ) ប្រយុទ្ធជាមួយនឹងពួកទេវតាអាក្រក់ដែលប្រឆាំងទាស់នឹងព្រះគ្រិស្ត។
- គ) នាំយកអ្នកជឿដែលបានស្លាប់ទៅឯនគរឋានសួគ៌។
- ឃ) ចាកចេញពីព្រះជាម្ចាស់នៅគ្រាចុងក្រោយ។

៥ គម្ពីរ១ពង្សាវតាក្សត្រ២២:១៩ បង្ហាញថាទេវតាដ៏វិសុទ្ធគឺនៅជុំវិញ
- ក) អស់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ ដើម្បីការពារអ្នកទាំងនោះ។
- ខ) អារក្សដើម្បីរារាំងកិច្ចការរបស់វា។
- គ) បល្ល័ង្ករបស់ព្រះជាម្ចាស់នៅឯនគរឋានសួគ៌។
- ឃ) ទេវតាអាក្រក់ដែលពួកគេបានឃុំឃាំង។

៦ ចូរអានគម្ពីរម៉ាថាយ ២៦:៥៣ ។ តើអ្វីខ្លះ ដែលបទគម្ពីរនេះប្រាប់អំពី ការរៀបចំនៃពួកទេវតាដ៏វិសុទ្ធ?

ក) គ្មានអ្វីនៅក្នុងខគម្ពីរនេះ ប្រាប់អំពីរបៀបដែលពួកទេវតាត្រូវបានរៀបចំបែបណានោះទេ។
ខ) ពួកទេវតាប្រហែលជា ត្រូវបានរៀបចំ ជាមួយនឹងរចនាសម្ព័ន្ធស្រដៀងទៅនឹងភូមិរបស់មនុស្ស។
គ) ពាក្យឃោធាថា "កងពល" បង្ហាញថាពួកទេវតាត្រូវបានរៀបចំឲ្យដូចជាទាហាន។
ឃ) យោងតាមបរិបទនេះ យើងជឿថា ពួកទេវតាត្រូវបានរៀបចំជាក្រុមចម្រៀង។

៧ គម្ពីរដានីយ៉ែល ១០:១៣,២០ បញ្ជាក់ថាទេវតាលេចមក ដើម្បីជះឥទ្ធិពលទៅលើ
ក) អារម្មណ៍របស់មនុស្ស
ខ) ភាវៈដែលនៅឯឋានបរមសុខ។
គ) ព្រះតម្រិះដ៏ឧត្ដមរបស់ព្រះជាម្ចាស់។
ឃ) ប្រទេសជាតិ និង កិច្ចការជាតិ។

៨ នៅក្នុងសាច់រឿងអំពីការបង្កើត ក្នុងគម្ពីរលោកុប្បត្តិ បង្ហាញថា មានតែមនុស្សប៉ុណ្ណោះដែលត្រូវបានបង្កើត
ក) ដោយកិច្ចការពិសេសរបស់ព្រះជាម្ចាស់។
ខ) ជាមួយនឹងសមត្ថភាពក្នុងការបរិភោគ។
គ) នៅថ្ងៃទីបី។
ឃ) នៅថ្ងៃទីប្រាំ។

៩ នៅពេលដែលយើងនិយាយថា យើងត្រូវបានបង្កើតមកឲ្យមានសណ្ឋានដូចព្រះជាម្ចាស់ យើងមានន័យថា យើងគឺជា
ក) ការចម្លងពីលក្ខណៈខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់សុទ្ធសាធ។
ខ) ភាវៈដែលអាចស្រឡាញ់គ្នាទៅវិញទៅមក។
គ) ភាវៈដែលមានបុគ្គលិកលក្ខណៈ ភាវៈ ដែលមានវិចារណញ្ញាណ និង មានភាពរីករាយ។
ឃ) ភាវៈដែលមានបុគ្គលិកលក្ខណៈ ភាវៈដែលមានវិចារណញ្ញាណ និង មានសីលធម៌។

១០ ទោះបីជាព្រះជាម្ចាស់ជាស្ដេចលើចក្រវាឡ ទ្រង់បានប្រទានឲ្យមនុស្សនូវ
ក) ទំនួលខុសត្រូវជាមួយនឹងអំណាចដែលប្រកបប្រាជ្ញាញាណ និង យុត្តិធម៌នៅលើពិភពលោក។
ខ) សេរីភាពក្នុងការគ្រប់គ្រងលើការបង្កើតផ្សេងទៀតនៅក្នុងពិភពលោក។
គ) បទបញ្ជាឲ្យគ្រប់គ្រងលើរបស់មានជីវិតទាំងអស់ផ្សេងទៀត។
ឃ) បទបញ្ជាឲ្យបង្កើតលោហៈធាតុ។

១១ ឆន្ទៈ និង មនសិការរបស់យើង បូករួមបញ្ចូលគ្នាបង្កើតបានជា
ក) ទិដ្ឋភាពនៃអារម្មណ៍ក្នុងខ្លួនយើង។
ខ) ទិដ្ឋភាពនៃសីលធម៌ក្នុងខ្លួនយើង។
គ) ទិដ្ឋភាពអរូបីរបស់យើង។
ឃ) ទិដ្ឋភាពបញ្ញារបស់យើង។

១២ "សម្លេងដែលនៅខាងក្នុង" ដែលធ្វើឲ្យមានសកម្មភាពនៃសីលធម៌គឺ

ក) បំណងចិត្តរបស់យើង

ខ) ប្រាថ្នារបស់យើង

គ) មនសិការបស់យើង

ឃ) គំនិតប្រកបដោយវិចារណញាណរបស់យើង

១៣ អំណាចដែលយើងមានក្នុងការធ្វើការជ្រើសរើស រឿងត្រឹមត្រូវ និង រឿងខុសឆ្គង គឺជា

ក) មនសិការរបស់យើង

ខ) សេរីភាពរបស់យើង

គ) គំនិតរបស់យើង

ឃ) ឆន្ទៈរបស់យើង

១៤ យោងទៅតាមគម្ពីរ២កូរិនថូស ៥:៦-៨ នៅពេលដែលរូបកាយរបស់គ្រិស្តបរិស័ទស្លាប់ទៅ ព្រលឹងរបស់គាត់នឹង

ក) ទៅនៅជាមួយនឹងព្រះគ្រិស្តភ្លាមៗ

ខ) ចូលទៅក្នុងសភាពមួយដូចការសម្រានលក់ រងចាំការយាងត្រឡប់របស់ព្រះគ្រិស្ត។

គ) លែងមានវត្តមានទៀតហើយ ប៉ុន្តែនឹងត្រូវបង្កើតជាថ្មីម្តងទៀត នៅពេលព្រះគ្រិស្តយាងត្រឡប់មកវិញ។

ឃ) ត្រូវបានស្រូបចូលទៅក្នុងព្រលឹងរបស់ព្រះជាម្ចាស់ ហើយក្លាយទៅជាតែមួយ ក្នុងទ្រង់។

១៥ អំពើបាបអាចត្រូវបាន កំណត់ន័យថា ជាការមិនស្តាប់បង្គាប់ និង ភាពបរាជ័យក្នុងការ

ក) ធ្វើតាមក្រឹត្យវិន័យរបស់ក្រុមជំនុំ។

ខ) ធ្វើតាមច្បាប់របស់ព្រះជាម្ចាស់។

គ) ស្តាប់តាមមនសិការរបស់យើង។

ឃ) ធ្វើការជ្រើសរើសឲ្យបានត្រឹមត្រូវ។

១៦ ដើមកំណើតនៃអំពើបាបគឺត្រូវបានគេឃើញនៅក្នុង

ក) ព្រះជាម្ចាស់

ខ) សាតាំង

គ) លោកអដាំ

ឃ) ទេវតារបស់សាតាំង

១៧ ជារឿងចាំបាច់ណាស់ ដែលព្រះជាម្ចាស់ត្រូវហាមឃាត់មិនឲ្យលោកអដាំ និង នាងអេវ៉ាបរិភោគផ្លែឈើមួយប្រភេទ ព្រោះ

ក) ទ្រង់មិនសព្វព្រះហឫទ័យឲ្យពួកគេយល់អំពីរឿងគ្រប់យ៉ាងនោះទេ។

ខ) ផ្លែឈើ នោះ គឺគ្រោះថ្នាក់សម្រាប់ពួកគេ។

គ) ពួកគេត្រូវការប្រើប្រាស់ឆន្ទៈសេរីរបស់ពួកគេ ហើយធ្វើការជ្រើសរើសតាមព្រះជាម្ចាស់ ឬ ប្រឆាំងទ្រង់។

ឃ) ទ្រង់សព្វព្រះហឫទ័យឲ្យពួកគេដឹងថា ពួកគេស្ថិតក្រោមក្ដីមេត្តារបស់ទ្រង់ ហើយគ្មានសេរីភាពឆន្ទៈនោះទេ។

១៨ នាងអេវ៉ាប្រព្រឹត្តិអំពើបាប ព្រោះនាង

ក) ចង់ស្វែងរកភាពរំដើបរំជួល

ខ) នាងគិតស្មានថាខ្លួនឆ្លាត។

គ) ជ្រើសរើសយកខ្លួនឯងមុនព្រះជាម្ចាស់

ឃ) ស្អប់អដាំ

១៩ ទាក់ទងទៅនឹងអំពើបាប "អំពើរំលង" គឺបានន័យថា

ក) ឆ្លងកាត់ព្រំដែនដែលព្រះជាម្ចាស់បានកំណត់

ខ) មិនអាចធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។

គ) តម្កើងខ្លួនឯង

ឃ) ការចេះអត់ទោស

២០ យោងតាមគម្ពីររ៉ូម ៨:១៩-២២ អំពើបាប បានជះឥទ្ធិពលទៅលើ

ក) តែមនុស្សប៉ុណ្ណោះ។

ខ) តែមនុស្ស និង ទេវតាប៉ុណ្ណោះ។

គ) តែមនុស្ស និង សត្វប៉ុណ្ណោះ។

ឃ) ស្នាព្រះហស្តទាំងអស់នៅក្នុង សាកលលោក។

# ការប្រឡងជំពូកទីបី

១ នៅពេលដែលនិយាយអំពីព្រះជាម្ចាស់ ពាក្យថា "ការបើកសម្តែង" មានន័យថាព្រះជាម្ចាស់

ក) បណ្តាលចិត្តឲ្យយើងយល់ពីទ្រង់ តាមរយៈអ្វីដែលយើងងាយមើលឃើញនៅក្នុងធម្មជាតិ

ខ) លាតត្រដាងមកកាន់យើង ពីអ្វីដែលយើងមិនអាចយល់ អំពីទ្រង់។

គ) បំភ្លឺយើងតាមរយៈវិញ្ញាណរបស់យើង អំពីការពិតដែលយើងបានយល់រួចហើយ។

ឃ) បំភ័យយើង ដោយប្រាប់យើងពីអ្វីដែលនឹងកើតឡើងនៅថ្ងៃអនាគត។

២ កំណត់ត្រាជាសំណេរ គឺល្អជាងប្រពៃណីនិយាយតគ្នា ព្រោះកំណត់ត្រាជាសំណេរ

ក) មិនផ្លាស់ប្តូរឡើយ ក្រោយពេលវាត្រូវបានសរសេរឡើង។

ខ) មិនងាយនឹងភ្លេច។

គ) មិនងាយនឹងផ្លាស់ប្តូរទេ។

ឃ) តែងតែសុក្រិត។

៣ ការនិយាយថាព្រះជាម្ចាស់ "បានបណ្តាលចិត្តឲ្យ" តែងបទគម្ពីរ មានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធ

ក) មានព្រះបន្ទូលប្រាប់អ្នកនិពន្ធ អំពីអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់បាន និង ដឹកនាំផ្លូវពួកគេ ក្នុងការសរសេរផងដែរ។

ខ) បញ្ជាផ្តាច់ការ ទៅលើគ្រប់ពាក្យដូចដែលមានសរសេរនៅក្នុងព្រះគម្ពីរ។

គ) ប្រទានឲ្យអ្នកនិពន្ធព្រះគម្ពីរនូវគំនិតផុសផុល ធ្វើការចែកចាយបន្ត។

ឃ) ប្រើប្រាស់តែពាក្យពិសេស សម្រាប់ធ្វើការសរសេរបទគម្ពីរ។

៤ គម្ពីរ២ធីម៉ូថេ៣:១៦ ប្រាប់យើងថាគ្រប់បទគម្ពីរទាំងអស់គឺ

ក) ពិតទាក់ទាញគួរឲ្យចង់អានណាស់។

ខ) ស័ក្តសមនឹងយកមកវែងញែកណាស់។

គ) ព្រះជាម្ចាស់បានបណ្តាលចិត្តឲ្យតែង។

ឃ) មានអាថ៌កំបាំងណាស់។

៥ "ភាពផ្តាច់មុខ" នៃបទគម្ពីរ មានន័យថាព្រះគម្ពីរគឺ

ក) ការបើកសម្តែងជាសំណេរទាំងស្រុងរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតរបស់ព្រះ។

ខ) ជាសៀវភៅតែមួយគត់ដែលថ្លែងប្រាប់អំពីដើមកំណើតរបស់ព្រះជាម្ចាស់។

គ) ការបើកសម្តែងជាលើកចុងក្រោយរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់។

ឃ) ការបើកសម្តែងតែមួយគត់ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់។

៦ នៅក្នុងច្បាប់ចម្លង និង ច្បាប់ដែលរក្សារបស់បទគម្ពីរ មានភស្តុតាងអំពី

ក) មានភាពខុសគ្នាខាងឯគោលលិទ្ធ យ៉ាងខ្លាំង នៅក្នុងហត្ថសំណេរនីមួយៗ។

ខ) សំណេរដែលមិនគួរឲ្យទុកចិត្តជាច្រើន ដែលធ្វើឲ្យខូចតម្លៃនៃព្រះគម្ពីរ។

គ) ភាពមិនខុសគ្នាសោះឡើយ រវាងហត្ថសំណេរនីមួយៗ។

ឃ) ការការពារ និង ការថែទាំយ៉ាងច្បាស់របស់ព្រះជាម្ចាស់ ក្នុងការរក្សាឲ្យហត្ថសំណេរនៅតែអាចទុកចិត្តបាន។

៧ ការបណ្ដាលចិត្តឲ្យតែងពីព្រះវិញ្ញាណដ៏វិសុទ្ធ នៃបទគម្ពីរគឺមានតែនៅក្នុង

ក) ហត្ថសំណេរដើមក្នុងសំណេរព្រះគម្ពីរតែប៉ុណ្ណោះ។

ខ) ការបកប្រែដំបូងទៅជាភាសាផ្សេងៗ នៃសំណេរព្រះគម្ពីរតែប៉ុណ្ណោះ។

គ) ការបកប្រែនៃសំណេរព្រះគម្ពីរដោយអ្នកប្រាជ្ញខ្លាំងបំផុត ទៅជាភាពថ្មីមួយទៀតប៉ុណ្ណោះ។

ឃ) កណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ ដោយលោកម៉ូសេ និង កណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មីដោយលោកប៉ូលប៉ុណ្ណោះ។

៨ បទគម្ពីរនីមួយៗ ត្រូវតែបានវិភាគ និង បកប្រែ តាមរយៈពន្លឺនៃ

ក) សេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរទាំងមូល។

ខ) ប្រពៃណីនៃក្រុមជំនុំទាំងមូល។

គ) កន្លែងត្រូវបានគេរកឃើញនៅក្នុងបរិបទខគម្ពីរនោះ។

ឃ) ចំណេះដឹងដែលល្អជាងគេ ដែលផ្អែកលើការសិក្សាភាសាដើម។

៩ ក្រុមជំនុំគឺជាការប្រកបគ្នាដែលត្រូវបានបង្កើតឡើងដ៏ពិសិដ្ឋ របស់មនុស្សរួមគ្នា

ក) នៅក្នុងសេចក្ដីសង្ឃឹមដូចគ្នា ថានឹងបានជីវិតមួយដែលល្អប្រសើរ។

ខ) ទាំងស្រុងទៅលើរបៀបថ្វាយបង្គំ របស់ពួកគេ។

គ) ផ្អែកលើការយល់ស្របគ្នាទៅលើគោលលទ្ធិ។

ឃ) ទៅវិញទៅមក និង ជាមួយព្រះជាម្ចាស់។

១០ គម្ពីរអេភេសូ១:១៩-២៣ បញ្ជាក់ថាក្រុមជំនុំមិនអាចនឹងបង្កើតបាននោះទេ រហូតក្រោយពី

ក) ពួកសាវ័កត្រូវបានបែកខ្ញែក ដោយការបៀតបៀន។

ខ) ថ្ងៃបុណ្យថ្ងៃទីហាសិប ដែលមានរៀបរាប់នៅក្នុងគម្ពីរកិច្ចការជំពូក២

គ) ការមានព្រះជន្មរស់ឡើងវិញ និង ការយាងត្រឡប់ទៅនគរស្ថានសួគ៌វិញរបស់ព្រះគ្រិស្ត។

ឃ) ពួកសាវ័កដំបូងទាំងដប់ពីររូបស្លាប់អស់ទៅ។

១១ គ្រិស្តបរិស័ទភាគច្រើន យល់ស្រប់គ្នាថា ក្រុមជំនុំចាប់ផ្ដើមជាផ្លូវការ

ក) នៅពេលដែលព្រះយេស៊ូប្រសូត

ខ) នៅពេលដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

គ) នៅពេលដែលព្រះយេស៊ូប្រែព្រះកាយរបស់ទ្រង់។

ឃ) នៅក្នុងថ្ងៃបុណ្យថ្ងៃទីហាសិប ដែលមានរៀបរាប់នៅក្នុងគម្ពីរកិច្ចការជំពូក ២។

១២ យោងតាមគម្ពីរយ៉ូហាន៤:២៣ ការថ្វាយបង្គំរបស់ក្រុមជំនុំ ត្រូវតែធ្វើឡើង

ក) ជាមួយការយកចិត្តយ៉ាងខ្លាំងទៅលើ ដែនកំណត់នៃកញ្ចប់ថវិកា។

ខ) យោងទៅតាមពិធីសាសនាសុទ្ធសាធ។

គ) នៅក្នុងព្រះវិញ្ញាណ និង សេចក្តីពិត។

ឃ) នៅក្នុងទីសាធារណៈ។

១៣ ការថ្វាយបង្គំរួមគ្នា គឺមានសារៈសំខាន់ណាស់ សម្រាប់ក្រុមជំនុំ ព្រោះពួកអ្នកជឿគឺ

ក) ជាទិដ្ឋភាពនៃសហគមន៍របស់ព្រះជាម្ចាស់ ដូចទៅនឹងបុគ្គលគ្រប់រូបដែរ។

ខ) មិនសំខាន់សម្រាប់ផែនការរបស់ព្រះជាម្ចាស់ ក្នុងការថ្វាយបង្គំនោះទេ។

គ) មិនអាចថ្វាយបង្គំព្រះជាម្ចាស់ តែម្នាក់ឯងផ្ទាល់ខ្លួនទេ។

ឃ) អាចធ្វើជាសក្ខីភាពនៅក្នុងទីសាធារណៈតែប៉ុណ្ណោះ។

១៤ គម្ពីរអេភេសូ ៤:១១-១៣ បង្រៀនយើងថា អ្នកជឿមានសារៈសំខាន់នៅក្នុងក្រុមជំនុំ ដើម្បី

ក) ទទួលបានការចាប់អារម្មណ៍ និង ការគោរព សម្រាប់ខ្លួនគេផ្ទាល់។

ខ) ពង្រឹង ឬ "កសាង" ព្រះកាយរបស់ព្រះគ្រិស្តទាំងមូល។

គ) នាំការចាប់អារម្មណ៍មកកាន់ក្រុមជំនុំ ដើម្បីឲ្យអ្នកដទៃអាចជឿដែរ។

ឃ) ធ្វើកិច្ចការថែទាំ ទាំងអស់ដើម្បីឲ្យអគារព្រះវិហារនៅតែអាចដំណើរបន្ត។

១៥ នៅពេលព្រះគ្រិស្ត យាងមកសម្រាប់អ្នកជឿ គេហៅថា

ក) ការឆក់យកអ្នកជឿឡើងទៅ

ខ) ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត។

គ) ទុក្ខវេទនារបស់អ្នកជឿគ្រប់គ្នា។

ឃ) ការយាងត្រឡប់មកវិញរបស់ព្រះគ្រិស្ត ប្រកបដោយឫទ្ធានុភាព និង សិរីរុងរឿង។

១៦ យោងតាមគម្ពីរ១កូរិនថូស១៥:៥០-៥៤ អ្នកជឿដែលនៅមានជីវិតរស់ នៅក្នុងនៃការឆក់យកឡើងទៅ នឹងផ្លាស់ប្តូរពីរ

ក) មនុស្សទៅជាទេវតា

ខ) មនុស្សដែលអាចស្លាប់ ទៅជាអមតៈ

គ) ពេញដោយទុក្ខព្រួយ ទៅជាមានអំណរ

ឃ) ខ្មាសអៀន ទៅជាមានភាពមោះមុត

១៧ ដើម្បីយល់ពី ពេលកំណត់នៃគ្រាចុងក្រោយ បទទំនាយសំខាន់ៗនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ គឺត្រូវបានគេឃើញមាននៅក្នុង

ក) គម្ពីរសុភាសិត

ខ) គម្ពីរទំនុកតម្កើង

គ) ដានីយ៉ែល

ឃ) យ៉ាកុប

១៨ បទទំនាយនៅក្នុងគម្ពីរដានីយ៉ែលជំពូក៩ ស្ដីអំពី "ស្ដេចដែលនឹងមកដល់" នៅក្នុងថ្ងៃចុងក្រោយរបស់អ៊ីស្រាអែល។ យើងក៏ស្គាល់ស្ដេចនោះថាជា

ក) សាតាំង

ខ) អ្នកប្រឆាំងនឹងព្រះគ្រិស្ដ

គ) ស្ដេចដ៏អាចកំបាំង

ឃ) អារក្សដែលមកពីទិសខាងកើត

១៩ នៅពេលដែលព្រះអម្ចាស់យាងត្រឡប់មកវិញ ប្រកបដោយឫទ្ធានុភាព និង សិរីរុងរឿង ទ្រង់នឹងបង្កើត

ក) ប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យជាសាកលមួយ ។

ខ) ព្រះរាជ្យដ៏សុចរិត ដែលចេញពីអឺរ៉ុបខាងលិចមក។

គ) សន្តិភាពដ៏ខ្លីមួយ បន្ទាប់មកសង្គ្រាមនៅអើម៉ាគេដូន។

ឃ) ព្រះរាជ្យដ៏សុចរិតជាសាកលមួយ ដែលមានរយៈពេលមួយពាន់ឆ្នាំ។

២០ យោងតាមគម្ពីរវិវរណៈ ២១:២២ យើងនឹងចំណាយពេលអស់កល្បជានិច្ច

ក) នៅលើផែនដីបន្ទាប់ពីព្រះជាម្ចាស់ ស្រោចស្រង់ហើយ។

ខ) ទីដ៏សែនឆ្ងាយនៅជ្រុងម្ខាងទៀត នៃចក្រវាឡ។

គ) ជាមួយព្រះជាម្ចាស់នៅក្នុងផ្ទៃមេឃថ្មី និង ផែនដីថ្មី។

ឃ) ជាមួយព្រះជាម្ចាស់នៅលើផែនដីថ្មី ប៉ុន្តែផ្ទៃមេឃដដែល។